# ដំណាំត្រសក់ចំណារ

## I. ការជ្រើសរើសពូជ:

គេប្រើប្រាស់ពូជ ២ប្រភេទគឺពូជនាំចូលដោយក្រុមហ៊ុនក្រៅប្រទេស និង ពូជប្រពៃណីដែលគេសន្សំទុកពីមួយឆ្នាំទៅមួយឆ្នាំច្រើនជំនាន់មកហើយ ។

១. ពូជនាំចូលឬពូជក្រុមហ៊ុន:

- ពូជស្ថានីយ៍ក្បាលកោះ KK1
- ពូជនៅទីផ្សារមកពី អ៊ីស្តវេស៊ីដ និង ពូជជាតៃមកពីប្រទេសថៃ

២. ពូជប្រពៃណីឬពូជក្នុងស្រុក:

ពូជនេះមានអាយុកាលលូតលាស់ខ្លី ដងដើមលូតលាស់យឺតកំពស់ដើមទាបមានដើមតូចស្លឹកល្អិតៗ ផ្លែមានច្រើនសណ្ឋានសាច់ជ្រាយទាន់ឆាប់ប្រែពណ៌ពីបៃតងទៅលឿងក្រោយពេលប្រមូលផលវាមានគ្រាប់ច្រើនសាច់ស្តើងសំបកស្តើង ប៉ុន្តែវាឆាប់ទទួលបានផលក្នុងករណីគ្រាប់ពូជទុកលើសពី ៥ខែឡើងទៅ ។






ពូជក្នុងស្រុក ពូជកូនកាត់

## II. វិធីសាស្ត្រដាំដុះត្រសក់

ដើម្បីទទួលបានទិន្នផលល្អ អ្នកដាំដុះត្រូវយល់ដឹងនូវបទពិសោធន៍ល្អៗជាច្រើនដូចជា:

### ១. ការរៀបចំដី និងរង

ដីដែលដាំត្រសក់ពីរដូវមុនមិនត្រូវយកមកដាំត្រសក់ឡើយ ដំបូងត្រូវប្រមូលយកស្មៅចេញអោយស្អាត ភ្ជួរដីហាលអោយបានច្រើនដង និងច្រើនថ្ងៃមុននឹងលើករងសំរាប់ដាំ ។ របៀបលើករងត្រូវលើករងតាមទិសទឹកហូរនៅរដូវវស្សា កំពស់រងជាមធ្យម ២៥-៣០សម ទទឹងរង ១ម ប្រវែង ១០-១៥ម ក្រោយមកយកជីកុំប៉ុស្ត ឬ ជីលាមកសត្វចំនួន ២-៣ បង្គីជី ១៥-១៥-១៥ ទំងន់ ១០០ក្រាម ជី 0-0-៤៦ ទំងន់ ១០០ក្រាម ជីទាំង៣មុខនេះទៅបាចលើផ្ទៃមួយរង ហើយជ្រុំលប់ជីនោះទៅក្នុងដីក្បៀររងអោយស្មើបង្ហាប់គែមរងអោយហាប់ទើបគ្របកៅស៊ូលើរង និងចោះរន្ធសំរាប់ដាំតាមន្លោះជួរ និង គុម្ព ៦០សម × ៤០សម ។

## ២. របៀបដាំត្រសក់



ការគ្របរងសំរាប់ដាំ




ថ្នាំផ្សិតសំរាប់លាយគ្រប់ពូជមុនដាំ

មុននឹងដាំគេត្រូវយកគ្រាប់ពូជមកហាលថ្ងៃអោយក្តៅ បន្ទាប់មកយកទៅដាក់ត្រាំទឹកធម្មតារយៈពេល៦-១០ម៉ោង រួចយកគ្រាប់ទៅផ្អាប់ដោយខ្ចប់នឹងក្រណាត់ស្អាតសើមដាក់ទុកមួយយប់ក្នុងធុងទឹកកកបិទជិត ។

ក្រោយពីពិនិត្យឃើញគ្រាប់ត្រសក់ដុះពន្លកបន្តិច១ គេយកថ្នាំការពារជំងឺផ្សិតប្រភេទខុបភើហាយដ្រុកសាយចំនួនមួយស្លាបព្រាបាយទៅលាយជាមួយគ្រាប់ត្រសក់ចំនួនប្រហែល ២ កំប៉ុងទឹកដោះគោ ទើបយកគ្រាប់ទៅដាំ ។

របៀបដាំដាក់គ្រាប់ត្រសក់នៅតាមរន្ធដែលចោះចំនួន៣គ្រាប់ក្នុងមួយគុម្ពក្នុងជំរៅ២-៣សមបន្ទាប់មកយកផេះអង្កាមដែលត្រាំទឹកអោយសាបមកគ្របពីលើគ្រាប់ត្រសក់ ហើយស្រោចទឹកអោយជោគភ្លាម ។

## III. ការថែទាំដំណាំត្រសក់

បន្ទាប់ពីពេលដាំដុះត្រសក់រហូតដល់ពេលប្រមូលផលគេត្រូវដឹងបញ្ហាសំរាប់ទប់ស្កាត់ដូចជា ៖

### ១. ការស្រោចទឹក

ត្រសក់ជាប្រភេទដំណាំត្រូវការទឹករាល់ថ្ងៃ ប៉ុន្តែវាមិនទាមទានូវភាពជោគជាំខ្លាំងទេ វានឹងបណ្តាលអោយត្រសក់កើតជំងឺលឿងស្លឹក ដូចនេះប្រសិនបើគ្មានភ្លៀវគេត្រូវស្រោចត្រសក់រាល់ថ្ងៃមួយថ្ងៃ១-២ដង ប៉ុន្តែបើមានភ្លៀងត្រូវបង្ហូរទឹកដក់នោះចេញអោយអស់ពីបាតរងភ្លាម១ ។ត្រសក់ត្រូវការទឹកខ្លាំងក្នុងវគ្គចេញផ្កាកង្វះទឹកក្នុងវគ្គនេះធ្វើអោយផ្កាត្រសក់ជ្រុះច្រើន ។

### ២. ការដកស្មៅ និងបន្ថែមជី

ក្រោយពីមានស្មៅដុះតាមចន្លោះរង ឬតាមរន្ធគុម្ព ត្រូវដកស្មៅចេញអោយស្អាតគ្រប់ដំណាក់កាលនៃការលូតលាស់របស់ត្រសក់ ។ ចំពោះការដាក់ជីបំប៉នបន្ថែមត្រូវចែកចេញជា៣វគ្គធំ១ គឺ:

- វគ្គលូតលាស់ក្រោយពីដាំបាន ១០-១៥ថ្ងៃត្រសក់មានស្លឹកចំនួន២-៣ គេត្រូវស្រោចជីអ៊ុយរ៉េបំប៉នបន្តិច១ គឺជីមួយស្លាបព្រាបាយលាយទឹកមួយ ធុង ១៥-១៨លីត្រ ស្រោចចំគុម្ពត្រសក់ ។ បន្ទាប់មកទៀតចន្លោះពី ១៥-២០ថ្ងៃ ត្រូវស្រោចម្តងទៀត ។